# អត្ថបទ

# បច្ចុប្បន្នភាពនៃការរីករាលដាលមេរោគអេដស៍ និងជំងឺអេដស៍ និងបញ្ហាប្រឈមនៅកម្ពុជា







**ក.មេរោគអេដស៍** ៖ ជាវីរុសដែលធ្វើឱ្យប្រព័ន្ធភាពស៊ាំ ឬប្រព័ន្ធការពាររាងកាយឱ្យចុះខ្សោយ។ (HIV : Human Immune-deficiency Virus )

**ខ.ជំងឺអេដស៍** ៖ ជាចង្កោមរោគសញ្ញា ដែលធ្វើឱ្យប្រព័ន្ធភាពស៊ាំរបស់មនុស្សចុះខ្សោយ។ ( AIDS : Acquired Immune Deficiency Syndrome )

**គ.របៀបឆ្លងនៃមេរោគអេដស៍៖**

- ការរួមភេទ ៖ ប្រុសនិងស្រី ប្រុសនិងប្រុស
- ការប៉ះពាល់ឈាម ឬបញ្ចូលឈាម
- ការប្រើប្រាស់ឧបករណ៍មុតរួមគ្នា ៖ ម្ជុល កាំបិតកោរ ឡាម ...
- ការឆ្លងពីម្តាយទៅកូន ៖ ក្នុងផ្ទៃ សម្រាល និង បំបៅដោះ

**ឃ.មេរោគអេដស៍នៅមានបន្តឆ្លងនៅឡើយ *(UNAIDS 2017)***

- នៅទូទាំងពិភពលោកអ្នកឆ្លងថ្មីមានប្រមាណ ១លាន៨សែននាក់
- រៀងរាល់ថ្ងៃ យុវវ័យប្រមាណ២៣០០នាក់ បានឆ្លងមេរោគអេដស៍ថ្មី

**ង.មិនទាន់មានថ្នាំព្យាបាលឱ្យជាសះស្បើយនៅឡើយទេ**

**ច.ស្ថានភាពការរីករាលដាលមេរោគអេដស៍/ជំងឺអេដស៍នាពេលបច្ចុប្បន្ន៖**

- នៅទូទាំងពិភពលោកមានអ្នករស់នៅជាមួយមេរោគអេដស៍ប្រមាណ៣៦លាន៧សែននាក់ ក្នុងឆ្នាំ២០១៦ (UNAIDS 2017)។
- អ្នកទទួលឱសថប្រឆាំងមេរោគអេដស៍មានប្រមាណតែ១៩លាន៥សែននាក់ ក្នុងឆ្នាំ២០១៦ ( UNAIDS 2017 ) ។
- អ្នកស្លាប់ដោយសារជំងឺអេដស៍មានប្រមាណ ១ លាននាក់ក្នុងឆ្នាំ២០១៦
- នៅកម្ពុជាមានប្រមាណ ៥៧២នាក់ ក្នុងនោះស្ត្រីប្រមាណ ៥០ % បានឆ្លង មេរោគអេដស៍ កាលក្នុងឆ្នាំ២០១៧កន្លងទៅ ។

## អត្រាផ្ទុកមេរោគអេដស៍ក្នុងចំណោមប្រជាជនទូទៅ (១៥-៤៩ឆ្នាំ) នៅកម្ពុជា




### ឆ.ស្ថានភាពនៃការផ្តល់សេវាថែទាំ និងព្យាបាល៖

- ចំនួនប៉ាន់ប្រមាណអ្នកផ្ទុកមេរោគអេដស៍ ៖ ៦៨៦៧៨នាក់
- អ្នកបានមកធ្វើតេស្តដឹងពីស្ថានភាពថាមានផ្ទុកគឺ ៖ ៨៦% = ៥៩០៦៣នាក់
- ៩៨% ក្នុងចំណោមអ្នកដឹងបានទទួលការព្យាបាល ដូច្នេះនៅ ២ % មិនបានព្យាបាល
- ប្រមាណ ២ % ដែលមិនទាន់បានទទួលការព្យាបាលគឺ = ១១៨១នាក់
- អ្នកមិនបានដឹងនិងមិនបានទទួលការព្យាបាលគឺ៖ ៩៦១៥+១១៨១ = ១០៧៩៦នាក់

### ជ.បញ្ហា៖

- តើពួកគាត់នៅទីណា ? តើអ្នកណាស្គាល់ពួកគាត់ ?
- តើពួកគាត់បានដឹងពីស្ថានភាពខ្លួនគាត់ឬទេ ?
- តើពួកគាត់នៅបន្តការចំលង ? (រួមភេទ ? ? ? ? )




ជ.ក្រុមណាខ្លះដែលងាយប្រឈម នឹងការឆ្លងមេរោគអេដស៍៖

- ស្ត្រីធ្វើការនៅគ្រឹះស្ថានកម្សាន្តសប្បាយមនុស្សពេញវ័យ៖
  - គ្រឹះស្ថានកម្សាន្ត ...៖ ខារ៉ាអូខេ បៀហ្គាដិន ម៉ាស្សា ក្លឹបកម្សាន្ត .........
  - ចំនួនប៉ាន់ស្មាន ៖ ៤០២០៥ នាក់ (GIS mapping in 2003 & 2016 plus additional estimation of unreachable ... )
  - អាត្រាផ្ទុកមេរោគអេដស៍ ៖ ៣.២% (NCHAD 2016)
  - អត្រាផ្ទុកមេរោគអេដស៍ ៖ ១១.១% ក្នុងចំណោមស្ត្រីឯករាជ្យ (IBSS 2016)
  - ៨៦.២% ស្ត្រីបានប្រើស្រោមអនាម័យជាប់លាប់ជាមួយអតិថិជន (IBSS 2016)
  - ២៧.១% នៃស្ត្រីធ្វើការនៅកន្លែងកម្សាន្ត ប្រើស្រោមអនាម័យ (IBSS 2016)
- បុរសរួមភេទជាមួយបុរស (*Size Estimation & IBBS 2014* )
  - ចំនួនប៉ាន់ស្មានមានសរុប ៣០៨៩១នាក់ ហើយ ៨៩% ជាអ្នកដែលសកម្មក្នុងការរួមភេទ
  - អត្រាផ្ទុកមេរោអេដស៍គឺ ២.៣%
  - ៦៥%ចេញមុខហើយ ៣៥%លាក់មុខ
  - ៦០%មានដៃគូភេទ ពីរ ឬច្រើនក្នុង១ ខែចុងក្រោយ
  - ៣០%មិនបានប្រើប្រាស់ស្រោមអនាម័យជាប់លាប់ ក្នុងការរួមភេទតាមរន្ធគូថ ក្នុង៦ ខែចុងក្រោយ

- **ផលប៉ះពាល់ដែលបណ្តាលមកពីជំងឺអេដស៍ (*Size Estimation & IBBS 2014* )**
  - បុគ្គល និងគ្រួសារ
  - ការសិក្សា ឬសាលា
  - សង្គម និងរដ្ឋាភិបាល
- **វិធីសាស្រ្តសម្រាប់ការពារមេរោគអេដស៍៖**
  - A = Abstinent : តមរួមភេទ
  - B = Be faithful : ស្មោះត្រង់មួយទល់មួយ
  - C = Condoms : ប្រើប្រាស់ស្រោមអនាម័យ។